ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ......៧៥៧......អពដ

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ មីនា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

## ស្តីពីការដាក់លិខិតប្រកាស និងបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ២០១៤

អនុលោមតាមខ្លឹមសារក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៥ ស្តីពីពន្ធប៉ាតង់ និងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងសារាចរណែនាំលេខ០០៤ សហវ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការអនុវត្តពន្ធប៉ាតង់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសទាំងអស់ ជ្រាបអំពីកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ២០១៤ ដូចខាងក្រោម÷

១-ពន្ធប៉ាតង់សម្រាប់ឆ្នាំ២០១៤ ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤។

២-អាជីវកម្មដ្ឋាន ដែលប្រកបមុខរបរច្រើនប្រភេទត្រូវបង់ពន្ធប៉ាតង់ផ្សេងៗគ្នា ទៅតាមប្រភេទមុខរបរនីមួយៗ ហើយប័ណ្ណប៉ាតង់មួយ សម្រាប់មុខរបរមួយ។

៣-អាជីវកម្មដ្ឋាន ដែលមានសាខានៅតាមខេត្ត-រាជធានីតែមួយ ដែលរួមគ្នាលក់ដូរ ឬផលិតមុខទំនិញដូចគ្នា មិនចាំបាច់បង់ពន្ធប៉ាតង់ផ្សេងគ្នាទេ។ ប្រសិនបើអាជីវកម្មដ្ឋាន ដែលមានសាខានៅតាមខេត្ត-រាជធានីផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ នៅខេត្ត-រាជធានីដែលសាខានោះស្ថិតនៅ។

៤-ប័ណ្ណប៉ាតង់មានតំលៃតែចំពោះអ្នកដែលមានឈ្មោះក្នុងប័ណ្ណប៉ាតង់តែប៉ុណ្ណោះ។ ករណីមានការផ្លាស់ប្តូរទីកន្លែងទៅខេត្ត-រាជធានីផ្សេង ឬ ផ្លាស់ប្តូរមុខរបរអាជីវកម្មថ្មី ត្រូវបង់ពន្ធប៉ាតង់ជាថ្មីម្តងទៀត។

៥-អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចបង់ប្រាក់ពន្ធ ឱ្យបានត្រឹមត្រូវទៅតាមពេលវេលាដែលបានកំណត់។ ក្នុងករណីមិនបានបង់ ឬព្យាយាមគេចវេះពីការបង់ប្រាក់ពន្ធប៉ាតង់ ឬមានការក្លែងបន្លំប័ណ្ណប៉ាតង់ នឹងត្រូវទទួលរងនូវទោសទណ្ឌដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។ អ្នកជាប់ពន្ធត្រូវដាក់តាំង ឬព្យួរប័ណ្ណប៉ាតង់ នៅទីកន្លែងប្រកបអាជីវកម្មគោលដើមរបស់ខ្លួន។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹម និងជឿជាក់ថា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសពិតជាយកចិត្តទុកដាក់អញ្ជើញមកដាក់លិខិតប្រកាស និងបង់ពន្ធប៉ាតង់ ឱ្យបានរួសរាន់ទាន់ពេលវេលាតាមច្បាប់កំណត់។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល